# មេរៀនទី ៨៥៖ ជនជាតិអ៊ីស្រាអែលសាងសង់រោងឧបោសថ

## និក្ខមនំ ៣៥៖៤ -៣៦៖៣៨

**មេរៀនសម្រាប់គ្រូ** *(យូធូបលីង)*៖ https://youtu.be/-gaWYpvpZfc

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/2QdSXaTmu-w

**គោលបំណង៖** ព្រះចង់ឲ្យយើងបំរើព្រះដោយអស់ពីចិត្ត និងធ្វើអោយល្អបំផុត

**ខគម្ពីរចងចាំ៖ អេភេសូ ៦៖៧** *"ទាំងបំរើដោយអំណរ ដូចជាបំរើដល់ព្រះអម្ចាស់ផង មិនមែនដូចជាបំរើមនុស្សឡើយ"។*

**ចំរៀង** *(យូធូបលីង)*៖

១. គឺជាការល្អដែលសរសើរព្រះ https://youtu.be/Z91SULEHfho

២. ចូរសរសើរព្រះយេស៊ូវ https://youtu.be/PtAbR7-xroM

៣. ពេលដែលព្រះវិញ្ញាណបរិសុទ្ធ https://youtu.be/RODHIMCRzw4

### ១. អធិស្ឋាន

### ២. ចំរៀង: *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «តើអ្វីជាអំណោយទានរបស់ខ្ញុំ?»



១.ឲ្យកុមារក្រោកឈរ ហើយនិយាយម្នាក់ម្តងពីអ្វីដែលគេគិតថា គេពូកែខាងផ្នែកនោះ។ ចំនុចទាំងនោះអាចជាការច្រៀង រាំ លេងកីឡា គូរគំនូរ មើលថែមិត្តភក្តិ ចិត្តល្អ ។ល។

២.សូមរំលឹកកុមារថាព្រះបានប្រទាន អំណោយទានដ៏វិសេសដល់មនុស្សគ្រប់គ្នា ដែលយើងអាចប្រើវាដើម្បីបំរើព្រះ និងរាស្ត្ររបស់ទ្រង់។

### ៤. ការណែនាំមេរៀន

ព្រះបានប្រទានឲ្យមនុស្សម្នាក់មានអំណោយទានពិសេសផ្សេងៗគ្នា ដើម្បីឲ្យយើងម្នាក់ៗត្រៀមខ្លួនយ៉ាងល្អឥតខ្ចោះ ដើម្បីធ្វើអ្វីដែលព្រះចង់ឲ្យយើងធ្វើ។ ការងាររបស់យើងគឺស្តាប់បង្គាប់ព្រះ និងធ្វើអំពើល្អទាំង-នោះ ទៅតាមផ្លូវដ៏ត្រឹមត្រូវនិងល្អបំផុតតាមដែលយើងអាចធ្វើបាន។ ពេលដែលយើងបំរើព្រះអស់ពីចិត្តគឺយើងបានបង្ហាញទ្រង់ថា តើយើងស្រឡាញ់ព្រះអង្គប៉ុនណា? ជនជាតិអ៊ីស្រាអែលបំរើព្រះនៅក្នុងផ្លូវដ៏ល្អបំផុត។ សូមស្វែងយល់ពីអ្វីដែលពួកគេបានធ្វើ។

### ៥. រឿងនៅក្នុងព្រះគម្ពីរ

ក្នុងសាច់រឿងនៃព្រះគម្ពីរបស់យើងនៅថ្ងៃនេះ និយាយពីព្រះបានបង្គាប់ឲ្យជនជាតិអ៊ីស្រាអែលសាងសង់រោងឧបោសថ។ រោងឧបោសថគឺដូចជាព្រះវិហារ ប៉ុន្តែត្រូវបានធ្វើពិតង់ដើម្បីធ្វើឲ្យមានភាពងាយស្រួលក្នុងការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។ ដោយសារតែជនជាតិអ៊ីស្រាអែលមិនទាន់បានចូលទៅក្នុងទឹកដីសន្យានៅឡើយ ពួកគេត្រូវផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។ នេះគឺជាមូលហេតុដែលព្រះបានឲ្យជនជាតិ អ៊ីស្រាអែលសាងសង់រោងឧបោសថនេះឡើង ដើម្បីឲ្យគេអាចផ្លាស់ទីវាបានយ៉ាងងាយស្រួល។ ព្រះបានបង្គាប់ឲ្យ មនុស្សទាំងអស់នោះយកសំភារៈដើម្បីសាងសង់រោងឧបោសថ។ ពួកគេ

បាននាំយក ក្រណាត់ ស្បែកសត្វ ឈើ មាស ប្រាក់ និងត្បូងមានតំលៃជាច្រើន ដើម្បីយកមកសង់ពោងឧបោសថ។

ព្រះអង្គមានមនុស្សសំណព្វរបស់ទ្រង់ម្នាក់ ដើម្បីឲ្យមើលការខុសត្រូវក្នុងការងារសាងសង់ពោងឧបោសថនេះ។ ទ្រង់បានជ្រើសរើស បេតសាលាល ធ្វើជាអ្នកទទួលខុសត្រូវ។ ព្រះបានប្រទានអំណោយទានដ៏ពិសេសដល់ បេតសាលាល ដូច្នេះគាត់នឹងធ្វើពោងឧបោសថឲ្យក្លាយជាទីកន្លែងដ៏វិសេស និងស្អាតសំរាប់ឲ្យមនុស្សថ្វាយបង្គំព្រះ។ បេតសាលាលបានបង្រៀនជាងទាំងនោះឲ្យចេះធ្វើការបានយ៉ាងល្អឥតខ្ចោះ។ ទាំងបេតសាលាល និងជាងផ្សេងទៀតបានប្រឹងប្រែងធ្វើការជាមួយគ្នាក្នុងការសាងសង់ ពោងឧបោសថយ៉ាងស្រស់ស្អាតសំរាប់ថ្វាយព្រះជាម្ចាស់។ បេតសាលាល និងជនជាតិអ៊ីស្រាអែលសប្បាយចិត្ត និងមានឆន្ទៈ ក្នុងការបំរើព្រះដោយជំនាញសាងសង់របស់ពួកគេ។ ព្រះសមនឹងទទួលបាននូវការបំរើដ៏ល្អឥតខ្ចោះរបស់យើង។ បេតសាលាលនិងជនជាតិអ៊ីស្រាអែលបានបំរើព្រះដោយល្អឥតខ្ចោះ ហើយយើងក៏អាចធ្វើបានដូចគ្នា។

## ៦. សំនួរពិភាក្សា

១. តើព្រះបានឲ្យជនជាតិអ៊ីស្រាអែលសាងសង់អ្វីថ្វាយទ្រង់? (*ពោងឧបោសថ*)

២. ហេតុអ្វីបានជាពោងឧបោសថសាងសង់ធ្វើពីតង់? (*សាងសង់ដូច្នេះគឺវាអាចផ្លាស់ទីបានដោយងាយស្រួល ពីព្រោះជនជាតិអ៊ីស្រាអែលមិនទាន់បានចូលទៅដល់ទឹកដីសន្យានៅឡើយទេ?*)

៣. តើព្រះបានជ្រើសរើសអ្នកណាដើម្បីធ្វើជាអ្នកមើលការខុសត្រូវលើការសាងសង់ពោងឧបោសថនេះ? (*បេតសាលាល*)

៤. តើប្អូនៗអាចបំរើព្រះបានតាមវិធីណាខ្លះ? (*មកព្រះវិហារ អានព្រះគម្ពីរ សំអាតព្រះវិហារ ជួយរៀបចំកៅអី យកចិត្តទុកដាក់អ្នកដទៃ ចែកចាយដំណឹងល្អរបស់ព្រះ គោរពឪពុកម្តាយ និងស្រឡាញ់មិត្តភក្ត្រ ។ល។*)

## ៧. ល្បែងកំសាន្ត «តើប្អូនអាចធ្វើបានទេ?»




១. គ្រូនឹងហៅកុមារម្នាក់ ហើយសួរទៅកុមារនោះថា "តើប្អូនអាចធ្វើបានដែរឬទេ?"

២. កុមារនឹងឆ្លើយថា "ចាស់/បាទ ខ្ញុំអាចធ្វើបាន!"

៣. បន្ទាប់មកគ្រូជ្រើសរើសអ្វីមួយដើម្បីឲ្យកុមារធ្វើ។ (*ឧ. ច្រៀង ចំរៀង ដូតតុ លោតចុះលោតឡើង និយាយអ្វីល្អៗ ទៅ មិត្តភក្តិ ផ្តល់ស្នាមញញឹមដ៏ស្រស់ស្អាត រត់ជុំវិញថ្នាក់រៀន ។ល។*)

៤. សូមឲ្យកុមារបានចូលរួមលេងល្បែងនេះគ្រប់ៗគ្នា

៥.រំឭកដល់កុមារថាយើងត្រូវមានឆន្ទៈ ដើម្បីបំរើព្រះនិងប្រឹងធ្វើការរបស់យើងអោយបានល្អ នៅពេលដែលយើងបំរើទ្រង់។

## ៨. ខគម្ពីរចងចាំ

**អេភេសូ ៦៖៧** *"ទាំងបំរើដោយអំណរ ដូចជាបំរើដល់ព្រះអម្ចាស់ផង មិនមែនដូចជាបំរើមនុស្សឡើយ"*។

## ៩. ហាត្ថកម្ម

**"ខ្ញុំនឹងបំរើព្រះ"** សូមអោយកុមារផាត់ពណ៌លើរូបភាពខាងក្រោម

## ១០. ចំរៀង

(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**

ទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូវបានផ្តល់ឲ្យយើងនូវឱកាសដើម្បីបំរើព្រះ។ ទ្រង់គឺជាមិត្តសម្លាញ់ ទ្រង់គឺជាព្រះអាទិករ ហើយទ្រង់គឺព្រះអង្គសង្គ្រោះ។ ការបំរើគឺជាជំរើសដែលយើងធ្វើប្រចាំថ្ងៃ។ តើអ្នកបានឆែកមើលពីការជំរុញចិត្តក្នុងការបម្រើរបស់អ្នកបានញឹកញាប់ប៉ុណ្ណា? ការជំរុញចិត្តក្នុងផ្លូវខុសអាចលួចយកព្រះពរ និងធ្វើឲ្យប្រសិទ្ធភាពក្នុងការបំរើរបស់អ្នកមានកម្រិត។ សូមមើលបញ្ជីនៅខាងក្រោម និងគោលបំណងនៃការឆ្លើយតបទៅនឹងប្រយោគទាំងអស់នេះ។

- ខ្ញុំបំរើដើម្បីផ្គាប់ចិត្តដល់...
- ខ្ញុំរកឃើញថាខ្ញុំជាអ្នកណានៅក្នុង...
- ខ្ញុំត្រូវតែបង្ហាញពីខ្លួនឯងតាមរយៈ...
- ខ្ញុំត្រូវពឹងលើ...

សំរាប់គ្រីស្ទបរិសទ្ធ័ការបំរើគឺចេញមកពីការអរព្រះគុណចំពោះសេចក្តីសង្គ្រោះ និងការង្វាយបង្គំដើម្បីគោរពប្រតិបត្តិដល់ព្រះអទិកររបស់យើង។ ប្រសិនបើយើងមិនបានបំរើដោយហេតុផលទាំងអស់នោះទេ ប្រហែលជាយើងពិតជាកំពុងតែបំរើខ្លួនឯងតែប៉ុណ្ណោះ។




សូមសរសេរខគម្ពីរចងចាំៈ____________________________

____________________________________________________

____________________________________________________

____________________________________________________

____________________________________________________

# ខ្ញុំនឹងបម្រើព្រះ



សូមសរសេរខគម្ពីរចងចាំៈ________________________

________________________________________

________________________________________

________________________________________